# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ១៤៧២ ព.ណក.ណ.ម

ថ្ងៃសុក្រ ៩កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០២៣

**ជម្រាបមក**

**លោក/លោកស្រីប្រធានក្រុមហ៊ុន អិន ស៊ី អិច**

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលម៉ូតូ និងគ្រឿងបន្លាស់ម៉ាក **"DREAM"**, **"WAVE"**, **"BeAT"**, **"SCOOPY"**, **"ZOOMER-X"**, **"CLICK"**, **"VARIO"**, **"PCX"**, **"ADV"**, **"MSX"**, **"GROM"**, **"CB150R"** និង **"CBR"** របស់ក្រុមហ៊ុន **អិន ស៊ី អិច** ក្នុងព្រះរាជាណាចក្រកម្ពុជា។

**យោង:**
- មាត្រា ៣ និងមាត្រា ១១នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **អិន ស៊ី អិច** ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន HONDA MOTOR CO., LTD. ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/១៣៤៥៩/00 ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/១៣៤៥៧/00 ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២០
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៦៣៨៦៩/១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៧៩៦៨៦/២០ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៦៣៧៥១/១៧ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៧
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/២៣៦១២/០៦ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៦
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៧៦១៧៩/២០ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៦៦៣២/១៨ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៧៣៦៣៩/១៩ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៩
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៦៨៧៥១/១៨ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៧០១០២/១៨ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៦៧៩២៤/១៨ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨
- វិញ្ញាបនបត្រចុះបញ្ជីម៉ាក លេខចុះបញ្ជី KH/៧៩០០៥/២០ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលម៉ូតូ និងគ្រឿងបន្លាស់ពាក់ម៉ាកខាងលើ របស់ក្រុមហ៊ុន **អិន ស៊ី អិច** ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានពីក្រុមហ៊ុន HONDA MOTOR CO., LTD. ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខដែលក្រសួងបានតម្កល់ទុករួចហើយ។

លិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះមានសុពលភាពរយៈពេល ០២(ពីរ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន HONDA MOTOR CO., LTD. ដែលជាម្ចាស់ម៉ាក។

ចាប់ពីក្រោយរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះអ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវផ្សព្វផ្សាយលិខិតខាងលើនេះជាបន្ទាន់ក្នុងទំព័រខាងមុខរបស់សារព័ត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា និងបណ្តាញសង្គមនានា ហើយត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**អ៊ុក-ប្រជា**

***<u>ចម្លងជូនៈ</u>***

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ* ***សម្តេចអគ្គមហាសេនាបតីតេជោ*** *នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចក្រឡាហោម* ***ស ខេង***
- *ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប)*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ - កាលប្បវត្តិ*